ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ១២២៨/២៧-១២-២០១២

**សាលដីកា**

លេខ១៩ក្រVIយ

ចុះថ្ងៃទី២១-៥-២០១៣

តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំ និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី១០-៥-២០១៣ដែលមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted]ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជី

លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ១២២៨ចុះថ្ងៃទី២៧-១២-២០១២រវាង៖

-**ជនជាប់ចោទឈ្មោះ** [redacted] **ដើមបណ្តឹងឧទ្ធរណ៍**)ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ កើតនៅភូមិ២ ឃុំគងពិសី ស្រុកអង្គរជ័យ ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃផ្ទះជួល ផ្លូវលេខ៤៣៤ ក្រុម៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]ម្តាយឈ្មោះ [redacted])នៅលីវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ២ឆ្នាំ ។ឃុំខ្លួនថ្ងៃទី២៦.៨.២០១១។មេធាវី [redacted]

**ត្រូវចោទពីបទ៖** ..សំរួលដោយចេតនាឲ្យជនណាម្នាក់ប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀន ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តនៅផ្ទះជួល ផ្លូវលេខ៤៣៤ ក្រុម៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ

Scanned by CamScanner

កាលពីថ្ងៃទី១៨-០២-២០១១តាមបញ្ញត្តិមាត្រា៣៥.២ថ្មី នៃច្បាប់វិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩-៤-២០១២របស់ឈ្មោះ [redacted] មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៤០ក្រ១-ង-/១១.៤.២០១២សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**<u>ដំណើររឿងមានដូចតទៅ៖</u>**

កាលថ្ងៃទី១៨-០២-២០១១វេលាម៉ោង១៥.០០នាទី កំលាំងសមត្ថកិច្ចនគរបាលរដ្ឋបាលទំនប់ទឹក បានសហការណ៍ជាមួយកំលាំងសាលាសង្កាត់ទំនប់ទឹក បានចុះល្បាតត្រួតពិនិត្យភូមិសាស្ត្រដែនដីរបស់ខ្លួន ហើយបានត្រួតពិនិត្យផ្ទះដែលឈ្មោ[redacted] ជួលស្នាក់នៅស្ថិតនៅផ្លូវលេខ៤៣៤ ក្រុម៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ បានប្រទះឃើញឧបករណ៍សំរាប់ជក់គ្រឿងញៀនចំនួន០២(ពីរ) និងទុយោជ័រ១ចំនួន ហើយសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ[redacted] ឈ្មោះ[redacted] ឈ្មោះ [redacted] និង ឈ្មោ[redacted] យកមកសាកសួរ ទើបដឹងថា ឈ្មោះ[redacted] បានទៅទិញគ្រឿងញៀនពីឈ្មោះ [redacted] ហៅ [redacted] ពីឈ្មោះ [redacted] ហៅ [redacted] ពីឈ្មោះ[redacted] យកមកលក់បន្តនូវឧបករណ៍សំរាប់ជក់គ្រឿងឲ្យអ្នកទាំងនោះជក់នៅផ្ទះដែលឈ្មោះ[redacted] ជួលស្នាក់នៅបន្តទៀត។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ៤០ក្រ១-ង-/១១.៤.២០១២សាលាដំបូងរាជធានីភ្នំពេញ សំរេចសេចក្តីដូចតទៅ៖

១.ផ្តន្ទាទោសឈ្មោ[redacted] ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន១៥(ប្រាំ)ឆ្នាំ និង ពិន័យជាប្រាក់ចំនួន១០.០០០.០០០៛(ដប់លានរៀល) ពីបទសំរួលដោយចេតនាឲ្យជនណាម្នាក់ប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀន ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តនៅផ្ទះជួល ផ្លូវលេខ៤៣៤ ក្រុម៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៨-០២-២០១១តាមបញ្ញត្តិមាត្រា៣៥.២ថ្មី នៃច្បាប់វិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.សាលក្រមនេះជំនុំជំរះនៅថ្ងៃទី២៨.៣.២០១២ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ និង មេធាវីការពារជនជាប់ចោទ ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍។

បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការសាលាឧទ្ធរណ៍។

**<u>នាពេលសវនាការ</u>**

ចៅក្រមអានរបាយការណ៍.

ជនជាប់ចោទឈ្មោះ[redacted] ឆ្លើយថា៖ ខ្លួនអាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ



Scanned by CamScanner

សំណាង កើតនៅភូមិ២ ឃុំគងពិសី ស្រុកអង្គរាំងពី ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃផ្ទះជួល ផ្លូវលេខ៤៣៤ ក្រុម៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted](រ) ម្ដាយឈ្មោះ[redacted](រ)នៅលីវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ២ឆ្នាំ ។ខ្លួនព្រមទទួលមេធាវី [redacted]ការពារឲ្យ។ខ្លួនប្ដឹងឧទ្ធរណ៍ ព្រោះតុលាការសំរេចដាក់ទោសខ្លួនរហូតដល់៥ឆ្នាំច្រើនពេក។កាលពីថ្ងៃទី១៨.០២.២០១១ខ្លួនបានជួលផ្ទះកើតហេតុខាងលើក្នុងតំលៃ៥០០០រៀលក្នុង១ថ្ងៃ ដើម្បីស្នាក់នៅ និង បានផ្ដល់ទីតាំងផ្ទះនេះដើម្បីឲ្យមិត្តភ័ក្តខ្លួនមកជក់២ទៅ៣ដងក្នុង១ថ្ងៃ បានកំរៃ១០.០០០៛ ទៅ១៥.០០០៛ ពីអ្នកមកជក់ថ្នាំញៀន ខ្លួនជាអ្នកផ្ដល់ថ្នាំញៀន និង មានឧបករណ៍សំរាប់ឲ្យមិត្តភ័ក្តខ្លួនម្នាក់ឈ្មោះ[redacted]ជក់ថ្នាំញៀន។ទិញថ្នាំញៀនម្ដងៗអស់៣ទៅ៤០.០០០៛ទុកលក់ឲ្យគេបានចំណេញចំនួន១០.០០០៛ប្រាកដមែន។ខ្លួនឈប់ជក់គ្រឿងញៀនយូរហើយ ។ ខ្លួនមានរឿងមួយទៀត តុលាការដាក់ទោសខ្លួនចំនួន២ឆ្នាំប៉ុណ្ណោះ ឯសំណុំរឿងនេះតុលាការដាក់ទោសខ្លួនរហូតដល់៥ឆ្នាំ។ខ្លួនសំណូមពរសុំបន្ធូរបន្ថយទោសដល់ខ្លួនឲ្យបានទាប និង សុំស្រាលទោស។

តំណាងមហាអយ្យការសន្និដ្ឋានថា៖ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួនគ្រប់ដំណាក់កាល។មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] ពីបទសំរួលដោយចេតនាឲ្យជនណាម្នាក់ប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀន ដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តនៅផ្ទះជួល ផ្លូវលេខ៤៣៤ ក្រុម៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៨-០២-២០១១តាមបញ្ញត្តិមាត្រា៣៥.២ថ្មី នៃច្បាប់វិសោធនកម្មច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។សុំតំកល់សាលក្រមព្រហ្មទណ្ឌលេខ៤០ក្រ១-ង-/១១.៤.២០១២សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ។

មេធាវី [redacted] សន្និដ្ឋានថា៖ខ្លួនជាមេធាវីការពារឈ្មោះ[redacted]កូនក្ដីខ្លួនបានឆ្លើយសារភាពរួចហើយ។កូនក្ដីខ្លួនមានសំណុំរឿង២ សំណុំរឿង១តុលាការសំរេចដាក់ទោស២ឆ្នាំ កូនក្ដីខ្លួនមិនប្ដឹងឧទ្ធរណ៍ទេ តែសំណុំរឿងនេះតុលាការសំរេចដាក់ទោសរហូតដល់ទៅ៥ឆ្នាំ កូនក្ដីខ្លួនប្ដឹងឧទ្ធរណ៍ ព្រោះដាក់ទោសច្រើនពេក កូនក្ដីខ្លួនបានសារភាពថាពិតជាបានឲ្យមិត្តភ័ក្តម្នាក់គត់មកជក់គ្រឿងញៀននៅផ្ទះរបស់គាត់មែន។សំណូមពរសុំតុលាការសំរេចបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួនឲ្យបានទាបផង និង សំណូមពរសុំតុលាការសំរេចស្រាលទោសឲ្យកូនក្ដីខ្លួនផង។

ក្រោយពីបានស្ដាប់ចំលើយជនត្រូវចោទ.

ក្រោយពីបានស្ដាប់តំណាងមហាអយ្យការសន្និដ្ឋាន.

ក្រោយពីបានស្ដាប់មេធាវីសន្និដ្ឋានការពារ.

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.



Scanned by CamScanner

## សាលាឧទ្ធរណ៍ យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩-៤-២០១២របស់ជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៤០ក្រ១-ង-/១១.៤.២០១២សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន។

២.ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួនគ្រប់ដំណាក់កាលថា កាលពីថ្ងៃទី១៨.០២.២០១១ខ្លួនបានជួលផ្ទះកើតហេតុខាងលើក្នុងតំលៃ៥០០០រៀលក្នុង១ថ្ងៃ ដើម្បីស្នាក់នៅ និង បានផ្តល់ទីតាំងផ្ទះនេះដើម្បីឲ្យមិត្តភ័ក្តខ្លួនមកជក់២ទៅ៣ដងក្នុង១ថ្ងៃ បានកំរៃ១០.០០០៛ ទៅ១៥.០០០៛ ពីអ្នកមកជក់ថ្នាំញៀន ខ្លួនជាអ្នកផ្តល់ថ្នាំញៀន និង មានឧបករណ៍សំរាប់ឲ្យមិត្តភ័ក្តខ្លួនជក់ថ្នាំញៀន។ហើយទិញថ្នាំញៀនម្តងៗអស់៣ទៅ៤០.០០០៛ ទុកលក់ឲ្យគេបានចំណេញ១០.០០០៛ប្រាកដមែន។

៣.រឿងក្តីនេះសាលាដំបូងបានលើកសំអាងហេតុមកបញ្ជាក់មានលក្ខណៈត្រឹមត្រូវហើយ ហេតុនេះសាលាឧទ្ធរណ៍ឯកភាពតាមសំអាងហេតុនេះទាំងស្រុង។

៤.សាលក្រមព្រហ្មទណ្ឌលេខ៤០ក្រ១-ង-/១១.៤.២០១២សាលាដំបូងរាជធានីភ្នំពេញសំរេចសេចក្តីមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និង អង្គច្បាប់ហើយ គួរតំកល់ទុកជាបានការ។

## ហេតុដូច្នេះ សម្រេចសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩-៤-២០១២របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២.តំកល់សាលក្រមព្រហ្មទណ្ឌលេខ៤០ក្រ១-ង-/១១.៤.២០១២សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

៣.បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី២១-៥-២០១៣ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| --- | --- | --- |
| ហត្ថលេខា [redacted] | [redacted] | [redacted] |

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី 29 ខែ 5 ឆ្នាំ២០១៣

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

**ក្រឡាបញ្ជី**



Scanned by CamScanner